# គោលគំនិតស្ដីពី
# សិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពី ចីរភាពប្រព័ន្ធអេកូឡូស៊ីអាងទន្លេ ក្នុងការអភិវឌ្ឍវារីអគ្គិសនី

## អំពីសិក្ខាសាលា

សិក្ខាសាលាមានគោលបំណង លើកកំពស់ការយល់ដឹងស្ដីពី ទស្សនៈទានចីរភាពនៃការអភិវឌ្ឍក្នុងអាងទន្លេមេគង្គក្រោម ជាពិសេស ការសាងសង់ទំនប់វារីអគ្គិសនី។ សិក្ខាសាលា នឹងផ្ដល់ចំណេះដឹង បទពិសោធន៍ ដល់អ្នកជំនាញ និងអ្នកដឹកនាំវ័យក្មេង ដែលជាអ្នករៀបចំ និងអនុវត្តគោលនយោបាយ នូវតវិយាបថ មេរៀនអនុវត្ត ដែលជួយដោះស្រាយ បញ្ហាសង្គម និងបរិស្ថាន នៃការអភិវឌ្ឍវារីអគ្គិសនី។

សិក្ខាសាលានេះ មានរយៈពេល២ថ្ងៃ (និងទស្សនៈកិច្ចសិក្សា១ថ្ងៃ បើអាច)។ សិក្ខាសាលាដឹកនាំរៀបចំ ដោយវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា សហការជាមួយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងឧបត្ថម្ភដោយ GIZ-MRC Program និង បណ្ដាញការងារ ដើម្បីអភិវឌ្ឍវារីអគ្គិនីប្រកបដោយចីរភាព នៃបណ្ដាប្រទេសទន្លេមេគង្គ (NSHD-M)។ សិក្ខាសាលានេះ ផ្ដល់ដោយមិនគិតប្រាក់។

## គ្រូបណ្ដុះបណ្ដាល

សិក្ខាសាលានេះ សម្របសម្រួល និងបង្រៀនដោយ គ្រូមានបទពិសោធន៍ មកពី វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងអ្នកអនុវត្តន៍ផ្ទាល់មានបទពិសោធន៍ជាក់ស្ដែង។

## អ្នកចូលរួម (សិក្ខាកាម)

មន្ត្រីជំនាញពាក់ព័ន្ធ៖ ថាមពល វារីអគ្គិសនី ការបរទេស និងសហប្រត្តិការអន្តរជាតិ ធនធានទឹកនិងឧតុនិយម បរិស្ថាន និងគ្រូឧទ្ទេស និងនិស្សិតថ្នាក់ឧត្តមសិក្សា ផ្នែកធនធានទឹក បរិស្ថាន និងអេកូឡូស៊ី។

**កាលបរិច្ឆេទ៖** ១៤ ដល់ ១៥ សីហា ឆ្នាំ២០១៨

**ទីកន្លែង៖** សណ្ឋាគារ កាំបូឌីយ៉ាណា ភ្នំពេញ ប្រទេសកម្ពុជា

**ទំនាក់ទំនង៖** sina@cdri.org.kh

